# 3. របៀបទទួលការថែទាំ

## ការថែទាំងាយអន់ចិត្ត

### សេវាការយល់ព្រមពីអនីតិជន

អ្នកអាចនឹងទទួលសេវា តែខាងក្រោមប៉ុណ្ណោះ ដោយគ្មានការអនុញ្ញាតពីមាតាបិតា ឬអាណាព្យាបាលរបស់អ្នក បើសិនអ្នកមានអាយុ 12 ឆ្នាំ ឬចាស់ជាង៖

- ថែទាំសុខភាពអារម្មណ៍ អ្នកជំងឺតដេកពេទ្យ សំរាប់ (អនីតិជន អាយុ 12 ឆ្នាំ ឬចាស់ជាង)៖
  - ការធ្វើបាបផ្លូវភេទ (គ្មានកម្រិតអាយុទាបជាង)
  - ស្ទន់អន្ទការនឹងពូជឯង
  - ការធ្វើបាបផ្លូវកាយ
  - ការធ្វើបាបក្មេង
  - នៅពេលអ្នកមានគំនិត ពីការធ្វើឲ្យខ្លួនអ្នក ឬមនុស្សដទៃឈឺចាប់ (អនីតិជនអាយុ 12 ឆ្នាំ ឬចាស់ជាង)
- ការការពារ/ការធ្វើតេស្ត/ការព្យាបាលជំងឺ HIV/AIDS
- ការការពារ/ការធ្វើតេស្ត/ការព្យាបាល ការឆ្លងកាមរោគ
- សេវាព្យាបាលវិបត្តិប្រើគ្រឿងញៀន (អនីតិជនអាយុ 12 ឆ្នាំ ឬចាស់ជាង)។ សំរាប់ព័ត៌មានថែមទៀត មើល "សេវាព្យាបាលវិបត្តិប្រើគ្រឿងញៀន" ក្នុងសៀវភៅណែនាំនេះ។

បើសិនអ្នក មានអាយុក្រោម 18 ឆ្នាំ អ្នកអាចទៅជួបវេជ្ជបណ្ឌិត ដោយគ្មានការយល់ព្រម ពីមាតាបិតា ឬអាណាព្យាបាលរបស់អ្នក សំរាប់ប្រភេទនៃការថែទាំទាំងនេះទេ៖

- ការមានគភ៌
- ការរៀបចំគំរោងគ្រួសារ/ការបង្ការមានកូន
- សេវាការពន្លូតកូន

សំរាប់ការធ្វើតេស្តគភ៌, សេវារៀបចំគំរោងគ្រួសារ, ការពារមានកូន, ឬសេវាការឆ្លងកាមរោគ, វេជ្ជបណ្ឌិត ឬវេជ្ជមន្ទីរ មិនបាច់ជាផ្នែកនៃបណ្តាញ Blue Shield Promise ទេ។ អ្នកអាចជ្រើសរើស អ្នកផ្តល់សេវានៃ Medi-Cal ណាមួយ ហើយទៅជួបគេ សំរាប់សេវាទាំងនេះ ដោយគ្មានការបញ្ជូន ឬការយល់ព្រមជាមុន (ការអនុញ្ញាតមុន) ឡើយ។ សេវាមកពីអ្នកផ្តល់សេវា នៅក្រៅបណ្តាញ ដែលមិនទាក់ទង នឹងការថែទាំងាយអន់ចិត្ត អាចនឹងមិនបាន រ៉ាប់រងទេ។ សំរាប់ជំនួយ ក្នុងការរកវេជ្ជបណ្ឌិត ឬវេជ្ជមន្ទីរ ដែលផ្តល់សេវាទាំងនេះ ឬសំរាប់ជំនួយ ដើម្បីទទួលសេវា ទាំងនេះ (រួមទាំងយានជំនិះ) អ្នកអាចហៅ 1-800-605-2556 (TTY 711)។

អនីតិជន អាចនិយាយទៅកាន់អ្នកតំណាងម្នាក់ ជាឯកជន អំពីកង្វល់នៃសុខភាពរបស់គេ ដោយហៅ ខ្សែឱវាទពេទ្យ Blue Shield Promise 24/7 លេខ 1-800-609-4166 (TTY 711)។

# 4. អត្ថប្រយោជន៍ និងសេវា

## គំរោងសុខភាពរបស់អ្នក រ៉ាប់រងអ្វីខ្លះ

ជំពូកនេះពន្យល់អំពី សេវាដែលរ៉ាប់រង របស់អ្នក ឋានៈជាសមាជិកនៃ Blue Shield Promise។ សេវាដែលរ៉ាប់រងរបស់អ្នក គឺឥតគិតថ្លៃឡើយ ដរាបណាវាគឺជាវេជ្ជសាស្ត្រចាំបាច់ និងបានផ្តល់ដោយអ្នក ផ្តល់សេវាក្នុងបណ្តាញ។ អ្នកត្រូវតែសូម ការយល់ព្រមជាមុន (ការអនុញ្ញាតមុន) ពីយើង បើសិនការថែទាំ គឺនៅក្រៅបណ្តាញ លើកលែងតែសេវាងាយអន់ចិត្ត ឬសេវាថែទាំជាអាសន្ន និងបន្ទាន់។ គំរោងសុខភាពរបស់អ្នក អាចនឹងរ៉ាប់រងសេវាវេជ្ជសាស្ត្រចាំបាច់ មកពីអ្នកផ្តល់សេវានៅក្រៅបណ្តាញ។ ប៉ុន្តែអ្នកត្រូវតែសូម ការយល់ព្រមជាមុន (ការអនុញ្ញាតមុន) ពី Blue Shield Promise សំរាប់ការនេះ។ សេវាវេជ្ជសាស្ត្រចាំបាច់ គឺសមហេតុផល និងជាចាំបាច់ ដើម្បីការពារជីវិតរបស់អ្នក, រក្សាអ្នកកុំឲ្យក្លាយជាឈឺថ្កាត់ធ្ងន់ធ្ងរ ឬពិការ, ឬបន្ថយការឈឺចាប់ធ្ងន់ធ្ងរ ពីជំងឺដែលបានវិនិច្ឆ័យ, ការឈឺថ្កាត់ ឬមានរបួស។ សំរាប់សមាជិក អាយុក្រោម 21 ឆ្នាំ សេវា Medi-Cal បញ្ចូលនូវការថែទាំដែលជាវេជ្ជសាស្ត្រចាំបាច់ ដើម្បីកែ ឬជួយសំរាល ជំងឺផ្លូវកាយ ឬផ្លូវចិត្ត ឬលក្ខណៈ។ សំរាប់សេចក្តីល្អិតល្អន់ថែមទៀត ស្តីពីសេវាដែលរ៉ាប់រងរបស់អ្នក ហៅលេខ 1-800-605-2556 (TTY 711)។

សំរាប់សមាជិក អាយុក្រោម 21 ឆ្នាំ ទទួលអត្ថប្រយោជន៍ និងសេវាបន្ថែម។ អានជំពូក 5៖ ថែទាំសុខុមាលក្មេង និងយុវវ័យ សំរាប់ព័ត៌មានថែមទៀត។

អត្ថប្រយោជន៍សុខភាព ជាគោលមួយចំនួន ដែល Blue Shield Promise ផ្តល់ជូន គឺមានចុះរាយខាងក្រោម។ អត្ថប្រយោជន៍ ដែលមានសញ្ញាផ្កាយ (*) អាចនឹងត្រូវការយល់ព្រមជាមុន។

- ចាក់ម្ជុលវិទ្យាសាស្ត្រ *
- វិធីព្យាបាលសុខភាពដុនដាប និងសេវាតាមផ្ទះ (ការព្យាបាលរយៈពេលខ្លី)
- ការចាក់ថ្នាំការពាររោគ (ចាក់ថ្នាំ) មនុស្សពេញវ័យ
- ការធ្វើតេស្ត និងការចាក់ថ្នាំ អាល់ឡែរជី
- សេវាឡានពេទ្យ សំរាប់ភាពអាសន្ន
- សេវាគ្រូពេទ្យថ្នាំស្ពឹក
- ការពារជំងឺហឺត
- សំនៀងវិទ្យា *
- ការព្យាបាលសុខភាពឥរិយាបថ *
- ការស្តារសមត្ថភាពបេះដូង
- សេវាចាប់សរសៃ *
- វិធីព្យាបាលគីម៉ូ និងវិធីព្យាបាលកម្មរស្មីវិទ្យុ
- ការប្រមាណសុខភាពបញ្ញា
- សេវាទន្ត - មានកម្រិត (បានធ្វើដោយអ្នកវិជ្ជាជីវៈពេទ្យ/PCP ក្នុងការិយាល័យពេទ្យ) *
- សេវាលាងវក្កំ/ប្រយ័តឈាម
- និរន្តរាយបរិក្ខារពេទ្យ (Durable Medical Equipment, DME) *
- ជួបពិគ្រោះនៅបន្ទប់សង្គ្រោះបន្ទាន់
- អាហារូបត្ថម្ភពោះវៀន និងខាងក្រៅពោះវៀន *
- ជួបពិគ្រោះនៅការិយាល័យ សំរាប់ការរៀបចំគំពោងគ្រួសារ និងការប្រឹក្សា (អ្នកអាចទៅជួបអ្នកផ្តល់សេវាមិនចូលរួម)
- សេវាសម្បទា និងឧបករណ៍ *
- ឧបករណ៍ជំនួយស្តាប់ *
- ថែទាំសុខភាពតាមផ្ទះ *
- ថែទាំជំងឺជិតស្លាប់ *
- ថែទាំសុខភាព និងវះកាត់ អ្នកជំងឺដេកពេទ្យ *
- មន្ទីរពិសោធន៍ និងវិទ្យុរស្មីព្យាបាល *
- វិធីព្យាបាលសុខភាព និងសេវា តាមផ្ទះយូរអង្វែង *
- ថែទាំម្តាយ និងទារកទើបកើត
- ផ្សាំសរីរាង្គធំៗ *
- វិធីព្យាបាលអាជីវកម្ម *
- ទម្រ/ឧបករណ៍សិប្បនិម្មិត *
- សំភារៈថង់លាមក និងបំពង់នោម
- សេវាអ្នកជំងឺឥតដេកពេទ្យ នៅមន្ទីរពេទ្យ
- សេវាសុខភាពអារម្មណ៍ អ្នកជំងឺឥតដេកពេទ្យ
- វះកាត់ អ្នកជំងឺឥតដេកពេទ្យ *
- ថែទាំកក់ក្តៅទំរាំស្លាប់ *
- ជួបពិគ្រោះ PCP
- សេវាពេទ្យកុមារ
- វិធីព្យាបាលរូបកាយ *
- សេវាប្រអប់ជើង *
- ការស្តារសមត្ថភាពសួត *
- សេវាសម្បទា និងឧបករណ៍ *
- សេវាគិលានុបដ្ឋាកម្មមានជំនាញ *
- ជួបពិគ្រោះអ្នកឯកទេស *
- វិធីព្យាបាលសំដី *
- សេវាការវះកាត់ *
- តេឡេថ្នាំពេទ្យ/តេឡេសុខភាព
- សេវាការប្តូរភេទ *
- ថែទាំបន្ទាន់
- សេវាចក្ខុវិញ្ញាណ
- សេវាសុខភាពរបស់ស្ត្រី

# អត្ថប្រយោជន៍ Medi-Cal បានរ៉ាប់រងដោយ Blue Shield Promise

## សេវាអ្នកជំងឺឥតដេកពេទ្យ (អាចដើរបាន)

### *ការប្រមាណសុខភាពបញ្ញា*

Blue Shield Promise រ៉ាប់រងការប្រមាណសុខភាពបញ្ញា គ្រួសៗប្រចាំឆ្នាំ សំរាប់សមាជិកអាយុ 65 ឆ្នាំ ឬចាស់ជាង និងបើមិនដូច្នេះទេ គ្មានសិទ្ធិទទួល ការប្រមាណស្រដៀងគ្នា ជាផ្នែកនៃពិគ្រោះផាសុកភាពប្រចាំឆ្នាំ នៅក្រោមកម្មវិធី Medicare ទេ។ ការប្រមាណសុខភាពបញ្ញា រកមើលសញ្ញានៃជំងឺវង្វេងវង្វាន់ ឬជំងឺវិកលសម្បជញ្ញៈ។